ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៥៥ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការគ្រប់គ្រងការនាំចេញផលិតផលរ៉ែ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខនស/រកម/០៧០១/០៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ
- បានឃើញអនុក្រឹត្យលេខ៥៧៦ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងរ៉ែនិងថាមពល
- បានឃើញអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងអាជ្ញាបណ្ណស្វែងរុករកនិងអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

## សម្រេច

**មាត្រា១ .-**

អនុក្រឹត្យនេះមានគោលបំណងគ្រប់គ្រងការនាំចេញផលិតផលរ៉ែ សំដៅទាញយកឱ្យបានជាអតិបរមានូវតម្លៃពីផលិតផលរ៉ែក្នុងការចូលរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចសង្គម។

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលដៅ៖

ក- កំណត់អំពីគោលការណ៍ជាមូលដ្ឋានក្នុងការវាយតម្លៃផលិតផលរ៉ែដែលអាចអនុញ្ញាតឱ្យនាំចេញ។

ខ- កំណត់អំពីលក្ខខណ្ឌនៃការអនុញ្ញាតឱ្យនាំចេញផលិតផលរ៉ែ។

**មាត្រា៣ .-**

អនុក្រឹត្យនេះមានវិសាលភាពគ្របដណ្តប់លើរាល់ការនាំចេញផលិតផលរ៉ែគ្រប់ប្រភេទ។

**មាត្រា៤ .-**

ផលិតផលរ៉ែ សំដៅដល់ផលិតផលរ៉ែដែលបានមកពីការធ្វើប្រតិបត្តិការធនធានរ៉ែរបស់សម្បទានិកដែលមានអាជ្ញាបណ្ណធនធានរ៉ែពីក្រសួងរ៉ែនិងថាមពល។

**មាត្រា៥ .-**

ផលិតផលរ៉ែគ្រប់ប្រភេទអាចត្រូវបានអនុញ្ញាតឱ្យនាំចេញស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងអនុក្រឹត្យនេះ លើកលែងតែផលិតផលរ៉ែដែលជារ៉ែអ៊ុយរ៉ានីញ៉ូមនិងរ៉ែវិទ្យុសកម្មផ្សេងទៀតត្រូវហាមឃាត់មិនឱ្យធ្វើការនាំចេញ។

**មាត្រា៦ .-**

ការអនុញ្ញាតឱ្យនាំចេញផលិតផលរ៉ែត្រូវផ្អែកលើការវាយតម្លៃឧត្តមភាពប្រៀបធៀបលើផលប្រយោជន៍សេដ្ឋកិច្ច សង្គម និងបរិស្ថាន។

**មាត្រា៧ .-**

ផលិតផលរ៉ែដែលអាចយកមកធ្វើប្រព្រឹត្តិកម្មបន្ត ឬកែច្នៃ ឬធ្វើជាវត្ថុធាតុដើមបម្រើឱ្យឧស្សាហកម្មក្នុងស្រុក ដូចជាផលិតផលរ៉ែដែលបានមកពីរ៉ែឧស្សាហកម្ម រ៉ែលោហៈ និងរ៉ែអលោហៈផ្សេងៗ មិនត្រូវបានអនុញ្ញាតឱ្យធ្វើការនាំចេញទេ លើកលែងតែក្នុងស្ថានភាពដូចខាងក្រោម រាជរដ្ឋាភិបាលអាចពិចារណាក្នុងការអនុញ្ញាតឱ្យធ្វើការនាំចេញបានៈ

- ផលប្រយោជន៍សេដ្ឋកិច្ចសង្គមរយៈពេលខ្លីនិងរយៈពេលវែងនៃការនាំចេញផលិតផលរ៉ែមានទំហំធំជាងការជំរុញឱ្យធ្វើប្រព្រឹត្តិកម្មបន្តឬកែច្នៃបន្តនៅក្នុងស្រុក
- ការធ្វើប្រព្រឹត្តិកម្មបន្តឬកែច្នៃបន្តផលិតផលរ៉ែនៅក្នុងស្រុកមានផលប៉ះពាល់អវិជ្ជមានដល់បរិស្ថាននិងសង្គមធ្ងន់ធ្ងរ
- ផលិតផលរ៉ែមានបរិមាណច្រើនលើសពីតម្រូវការផ្គត់ផ្គង់ឧស្សាហកម្មក្នុងស្រុក ហើយមិនមែនជាប្រភេទផលិតផលរ៉ែដែលត្រូវបានហាមឃាត់ពីរាជរដ្ឋាភិបាលក្នុងការនាំចេញ។

ក្រសួងរ៉ែនិងថាមពលត្រូវស្នើសុំគោលការណ៍សម្រេចពីរាជរដ្ឋាភិបាលជាមុនតាមរយៈក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មុនផ្តល់លិខិតអនុញ្ញាតឱ្យធ្វើការនាំចេញផលិតផលរ៉ែដូចខាងលើ។

**មាត្រា៨ .-**

ផលិតផលរ៉ែដែលមិនមានសក្តានុពលសេដ្ឋកិច្ចខ្ពស់ក្នុងការយកទៅកែច្នៃបន្តឬធ្វើជាវត្ថុធាតុដើមបម្រើឱ្យឧស្សាហកម្មក្នុងស្រុក ដូចជាផលិតផលរ៉ែសំណង់ ថ្មក្រានីត ថ្មអារ ឬថ្មប្លុកផ្សេងៗដែលមានបរិមាណ

ច្រើនលើសពីតម្រូវការផ្គត់ផ្គង់ក្នុងស្រុក អាចអនុញ្ញាតឱ្យនាំចេញបានដោយត្រូវសុំលិខិតអនុញ្ញាតនាំចេញពីក្រសួងរ៉ែនិងថាមពល។

**មាត្រា៩.-**

នីតិវិធីនិងបែបបទសម្រាប់ការស្នើសុំនាំចេញផលិតផលរ៉ែដូចមានចែងក្នុងមាត្រា៧និងមាត្រា៨ខាងលើត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងរ៉ែនិងថាមពល។

**មាត្រា១០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា
**រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

**ស៊ុយ សែម**

**កន្លែងទទួល** :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ